# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៥៦០ រប-៩៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំសូមជម្រាបឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ជ្រាបថា ការទទួលខុសត្រូវរបស់យើង(រាជរដ្ឋាភិបាល) ខាងសណ្តាប់ធ្នាប់នឹងសន្តិសុខសាធារណៈក្នុងរយៈពេលរៀបចំការបោះឆ្នោតនិងនៅពេលបោះឆ្នោត នៅថ្ងៃទី២៦ កក្កដា ១៩៩៨ ខាងមុខនេះ ជាកត្តាមួយសំខាន់ណាស់ដែលជាមូលដ្ឋានធ្វើឱ្យសាធារណៈមតិជាតិនិងអន្តរជាតិទទួលស្គាល់ ឬមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតនេះ ។

សហគមអន្តរជាតិ ព្រមទាំងអង្គការសហប្រជាជាតិផងអាចទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតនេះបើគណៈកម្មាធិការរៀបចំការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ខេត្ត,ឃុំ និងថ្នាក់ការិយាល័យ ដំណើរការទៅបានដោយអ្វីដែលគេហៅថា សេរី យុត្តិធម៌ ឱ្យគេអាចជឿទុកចិត្តបាន ប៉ុន្តែបើបសិនជាគណបក្សណាមួយដែលសហគមអន្តរជាតិនិងអង្គការសហប្រជាជាតិគេគាំទ្រនោះចាញ់ឆ្នោត ទោះបីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគ្រប់ជាន់ថ្នាក់បានដំណើរការល្អត្រឹមត្រូវ តាមការទាមទាររបស់គេក៏ដោយគេនៅមានលេសមួយមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ដោយប្រើទឡ្ហីករណ៍ថា ការបោះឆ្នោតនោះបានដំណើរការក្នុងបរិយាកាសគំរាមកំហែងបំភិតបំភ័យបង្ខិតបង្ខំឥតមានសន្តិសុខ ។

ហេតុនេះខ្ញុំយល់ថាយើងត្រូវតែចាត់វិធានការម៉ឺងម៉ាត់បំផុតកុំឱ្យគេយកលេសនោះទៅប្រើបាន ។ ភារកិច្ចធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈជូនប្រជាជនជាភារកិច្ចជាមូលដ្ឋាននិងជាចម្បងរបស់រាជរដ្ឋាភិបាលដែលត្រូវតែធានាឱ្យបានដាច់ខាត ។

បើគេលើកទឡ្ហីករណ៍ខាងលើនេះមកប្រើ រាជរដ្ឋាភិបាលទទួលខុសត្រូវទាំងស្រុងឥតមានអ្វីលើកឆ្លើយតបនឹងគេបានទេ អាស្រ័យហេតុនេះហើយបានជាខ្ញុំ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលមិនមែនជាអ្នកទទួលខុសត្រូវជាច់មុខតែម្នាក់ឯងក្នុងការធានាសណ្តាប់ធ្នាប់ និងសន្តិសុខជូនប្រជជន ខ្ញុំបានសម្រេចចិត្តថា ក្រសួងយុត្តិធម៌ត្រូវហ៊ានពុះពារ ចាត់គ្រប់វិធានការណ៍ចាំបាច់ ដើម្បីធានាកត្តាទាំងពីរខាងលើនេះឱ្យបានដាច់ខាត ។

១-ពីថ្ងៃម្សិលមិញនេះ,ទី១១ មិថុនា ១៩៩៨ ខ្ញុំបានកោះប្រជុំប្រធានតុលាការ និងព្រះរាជអាជ្ញគ្រប់ខេត្ត ក្រុងទូទាំងប្រទេស ដើម្បីបំភ្លឺឱ្យមានទស្សនៈច្បាស់លាស់អំពីការទទួលខុសត្រូវរបស់ខ្លួនម្នាក់ៗទោះបីការទទួលខុសត្រូវនេះជាការទទួលខុសត្រូវមានកម្រិតក៏ដោយ ពីព្រោះតុលាការ(ចៅក្រម) និងអយ្យការ(ព្រះរាជអាជ្ញា) មិនមែនមានតួនាទីនិងភារកិច្ចស៊ើបការ ឃ្លាំមើល តាមដាន និងចាប់ឃាត់ខ្លួនជនល្មើសទេ ។ នេះជាតួនាទីរបស់នគរបាល កងរាជអាវុធហត្ថ កងជីវពល (MilicePopulaire) ។

ការចាត់ចែង ការលើកផែនការ ការបែងចែកកម្លាំង ការតាមដានរកអំពើរំលោភច្បាប់ឬរំលោភសិទ្ធិរបស់មនុស្សជាតួនទីនិងភារកិច្ចចម្បងរបស់មន្ត្រីយុត្តិធម៌ដែលច្បាប់កំណត់ក្នុងមាត្រា៣៥,៣៦,៣៧,៣៨ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី២៨ មករា ១៩៩៣ ដូចមានស្រង់ជូនជាប់មកជាមួយនេះ ។

ប៉ុន្តែនៅពេលដែលមានកើតហេតុ មន្ត្រីយុត្តិធម៌ត្រូវនៅក្រោមបញ្ជារបស់អយ្យការ(ព្រះរាជអាជ្ញា) និងក្រោមបញ្ជារបស់តុលាការ (ចៅក្រមស៊ើបសួរមាត្រា ៣៦នៃច្បាប់ ស្តីពីធីតិវិធីព្រហ្មទណ្ឌខាងលើនេះ ។

ការកោះប្រជុំនេះ គឺជាការសម្រេចដាច់ខាតក្រោមការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលចង់ជៀសវាងមិនឱ្យរាជរដ្ឋាភិបាលទទួលខុសត្រូវក្នុងការចោទប្រកាន់របស់មតិជាតិនិងអន្តរជាតិ ដែលប្រឆាំងនិងយើង ហើយម្យ៉ាងទៀត បន្ទាប់ពីការបោះឆ្នោតទៅយើងនឹងមានលទ្ធភាពទៅកាន់នីតិរដ្ឋបានឆាប់រហ័ស ។

២-ខ្ញុំបានកំណត់អោយព្រះរាជអាជ្ញាទទួលខុសត្រូវមុនគេបង្អស់ចំពោះហេតុការណ៍អ្វីដែលកើតឡើង ហើយប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់សន្តិសុខរបស់ប្រជាជន នៅគ្រប់ជាន់ថ្នាក់ ខេត្ត ស្រុក ឃុំ ភូមិ ចាប់តាំងពីថ្ងៃនេះតទៅ សភាពការណ៍ក្នុងទូទាំងប្រទេសកម្ពុជាត្រូវតែស្ងប់ស្ងាត់ស្ងៀម មន្ត្រីរាជការគ្រប់ឋានៈនិងប្រជាជនទាំងអស់ក្នុងភូមិឃុំត្រូវតែគោរពច្បាប់ និងគោរពសិទ្ធិមនុស្ស ប្រជាជននៅជនបទក៏ដូចជានៅជុំវិញទីផ្សារត្រូវរស់នៅក្នុងសុខសន្តិភាព ។

៣-ខ្ញុំសូមបញ្ជាក់ថាព្រះរាជអាជ្ញានិងចៅក្រមគ្មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីបំពេញសមត្ថកិច្ចនិងបេសកកម្មដ៏មានតម្លៃធំធេងនេះទេ ។

ខ្ញុំសូមក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋាននគរបាលជាតិ អគ្គសេនាធិការកងយោធពលខេមរៈភូមិន្ទ និងបញ្ជារការដ្ឋានកងរាជអាវុធហត្ថជាតិ ដែលក្តាប់តម្រួតគ្រប់ប្រភេទ នគរបាលនិងកងរាជអាវុធហត្ថគ្រប់ជាន់ថ្នាក់រហូតដល់ភូមិ រួមសហការអនុវត្តឱ្យបានម៉ឺងម៉ាត់បំផុតនូវតួនាទីនិងភារកិច្ចរបស់គេទូទាំងប្រទេស ។

នគរបាលគ្រប់ប្រភេទ ត្រូវជូនដំណឹងមកអយ្យការអមតុលាការជាបន្ទាន់ ទោះបីថ្ងៃ ទោះបីយប់ ទោះបីកំពុងពេលហូបបាយ ឬកំពុងពេលសម្រាក អំពីសភាពការណ៍ប្លែកដែលកើតមានឡើង តុលាការ និង អយ្យការមានអ្នកយាមប្រចាំការ ២៤ ម៉ោងជាប្រចាំ។ ទោះបីពេលថ្ងៃ ឬពេលយប់អធ្រាត ចាត់ការភ្លាមមួយរំពេច ។ បើហេតុដែលបានកើតឡើងមានសភាពធ្ងន់ធ្ងរ ដូចចោរប្លន់ សម្លាប់មនុស្ស ដុតផ្ទះដុតផ្ទះសម្បែង វត្ត គប់គ្រាប់បែក ។ល។ ព្រះរាអាជ្ញាអាជ្ញាត្រូវចុះខ្លួនឯងដល់ទីកន្លែងដើម្បីក្តាប់សភាពការណ៍ និងបញ្ជាទិសឱ្យនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតភ្លាមៗ ហើយត្រូវតាមដានការស៊ើបអង្កេតនោះ រកអ្នកប្រព្រឹត្ត ឬអ្នកដៃជើងរបស់វា និងអ្នកសមគំនិត ឱ្យបានក្នុងរយៈពេលខ្លីបំផុត ហើយត្រូវតែពុះពារកុំឱ្យពួកអស់នេះគេចខ្លួនបាន ។

៤-ខ្ញុំសុំយ៉ាងទទូចឱ្យមានការជួយសហការយ៉ាងសកម្មពីកងជីវពល ពីព្រោះកងជីវពលរស់នៅក្នុងភូមិរបស់គេ គេជាកូនចៅរបស់ប្រជាជន ហើយគេស្គាល់មនុស្សក្នុងភូមិច្បាស់ណាស់ ហើយស្គាល់ភូមិសាស្ត្រ ក្រឡុកក្រលាតតមានអ្នកមកពីចម្ងាយចូលមកប្រព្រឹត្តអំពើល្មើស ឬមកលាក់ខ្លួនពួនអាត្មាបានឡើយ ។ ជីវពលត្រូវសហការជិតស្និតជាប់ជាប្រចាំទាំងថ្ងៃទាំងយប់ជាមួយនគរបាលដែលមានគ្នាតែ ៤ ឬ ៥ នាក់ប៉ុណ្ណោះនៅក្នុងឃុំនីមួយៗ ។

៥-ខ្ញុំបានចេញបញ្ជារួចហើយ តាំងពីសម្តេចនាយកដ្ឋមន្ត្រីទីពីរបានលើកឡើងនូវវិធានការណ៍៨ ចំណុចដើម្បីបំបាត់អំពើរំលោភច្បាប់ ។ គ្រប់ចៅក្រមនៅគ្រប់តុលាការបានទទួលការណែនាំពីក្រសួងយុត្តិធម៌ឱ្យផ្តន្ទាទោសអតិបរមា ក្នុងរឿងនីមួយៗដែលប៉ះពាល់ដល់សិទ្ធិមនុស្ស ជាពិសេសប៉ះពាល់ដល់សេចក្តីសម្រេច៨.ខ.នេះ ជាពិសេសរឿងកាន់ប្រើប្រាស់ ឬដឹកអាវុធខុសច្បាប់ ។

៦-រឿងអាវុធ យើងត្រូវពុះពារគ្រប់គ្រងឱ្យបានដាច់ខាត បើពុំនោះទេការខិតខំយ៉ាងណាក៏ដោយ និងត្រូវបរាជ័យជៀសមិនរួច ។ ខ្ញុំយល់ថារឿងឈ្មួញលួចលាក់លក់អាវុធគ្រប់ប្រភេទជាពិសេសនៅផ្សារដីហុយខណ្ឌឫស្សីកែវ ត្រូវបំបាត់ឱ្យអស់ជាដាច់ខាត ។ សាលាក្រុងភ្នំពេញ ខណ្ឌឫស្សីកែវ ស្នងការនគរបាលក្រុង និងមេបញ្ជាការកងរាជអាវុធហត្ថ ដែលមានសមត្ថកិច្ចលើដែនដីនោះ ជាអ្នកទទួលខុសត្រូវ បើនៅតែមានអាវុធ ឬឯកសណ្ឋាន លក់ទៀត

អ្នកទទួលខុសត្រូវៗផ្លាស់ចេញក្នុង២៤ម៉ោង ដាក់អ្នកថ្មីទៅជំនួស ។ បើការស៊ើបអង្កេតបង្ហាញឱ្យឃើញមានការសមគំនិតពីមន្ត្រីរាជការណាមួយ មន្ត្រីនោះត្រូវដាក់ទៅតុលាការផ្តន្ទាទោស ។

៧-ក្នុងរឿងទាំងអស់នេះតុលាការបានទទួលបញ្ជាឱ្យដើរផ្លូវកាត់(តាមច្បាប់ មិនមែនមនរំលោភច្បាប់ទេ) ដើម្បីជំនុំជម្រះឱ្យបានឆាប់បំផុត ចំពោះករណីដែលខ្ញុំបានលើកជូនខាងលើ ។

៨-ខ្ញុំសូមក្រសួងពាក់ព័ន្ធ ជាពិសេសក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថជាតិ អគ្គសេនាធិការកងយោធពលខេមរៈភូមិន្ទ ក្រសួងការពារជាតិ សូមក្រសួងទាំងអស់ជួយណែនាំគ្រប់ខេត្ត-ក្រុង ស្រុក ឃុំ ឱ្យមន្ត្រីនគរបាលយុត្តិធម៌រួមសហការយ៉ាងសកម្មបំផុតជាមួយអយ្យការ និងតុលាការ ស្តាប់បញ្ជារបស់ព្រះរាជអាជ្ញានឹងចៅក្រមស៊ើបសួរ ហើយត្រូវស្តាប់បញ្ជារបស់ថ្នាក់ដឹកនាំជាអភិបាលខេត្តក្រុង ស្តាប់បញ្ជារបស់ថ្នាក់ដឹកនាំស្រុក ស្តាប់បញ្ជារបស់មន្ត្រីឃុំ ហើយជាពិសេសស្តាប់បញ្ជារបស់តុលាការអយ្យការ ទាំងថ្ងៃទាំងយប់នៅពេលកើតហេតុអ្វីមួយដោយការរៀបចំទុកជាមុន ឬដោយចៃដន្យ ។

ខ្ញុំសូមឯកឧត្តមនាយកជួមន្ត្រីទីមួយ និងសម្តេចនាយករដ្ឋមន្ត្រីទីពីរមេត្តាជួយជំរុញវិធានការទូលំលាយនេះឱ្យសម្រេចខាងតែបានក្នុងកាលៈទេសៈដែលយើងយកឈ្នះឱ្យទាល់តែបាននេះ ។

៩-នៅទីបញ្ចប់ខ្ញុំសូមអភិបាលខេត្តមេត្តាជួយផ្តល់ប្រេងឥន្ធនៈខ្លះៗសម្រាប់តុលាការ អយ្យការចុះធ្វើការផ្ទាល់នៅមូលដ្ឋានខ្លួនផង ។ ពីព្រោះសព្វថ្ងៃសូម្បីតែទូរស័ព្ទក៏ហិរញ្ញវត្ថុខេត្តក្រុងមិនអនុញ្ញាតឱ្យមានថវិកាចាយសម្រាប់សងគេដែរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រព្រះរាជអធិបតី ឧ.ក្រ.ច
-សម្តេចប្រធានសភាជាតិ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ក្រសួងមហាផ្ទៃ
-អគ្គនាយកដ្ឋាននគរបាលជាតិ
-ក្រសួងការពារជាតិ
-អគ្គសេនាធិការកងយោធពលខេមរៈភូមិន្ទ
-បញ្ជាការកងរាជអាវុធហត្ថជាតិ
-អភិបាលខេត្ត-ក្រុងទូទាំងប្រទេស
-អភិបាលគ្រប់ស្រុក ខណ្ឌ
-មេឃុំគ្រប់ឃុំ សង្កាត់
-តុលាការគ្រប់ខេត្ត ក្រុង
-តុលាការយោធា
-អយ្យការយោធា